**ព្រះរាជាណាចក្រកម្ពុជា**

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ថ្លែងក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សា ២០១៧ - ២០១៨
## រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧

*- សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*

*- សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី*

*- សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស បងប្អូនជនរួមជាតិទាំងអស់ជាទីស្នេហា !*

**ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៧** នេះ ជាថ្ងៃដ៏មានអត្ថន័យជ្រាលជ្រៅបំផុតរបស់ព្រះរាជាណាចក្រកម្ពុជា ដែលត្រូវប្រារព្ធ**ពិធីបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០១៧- ២០១៨** ។ ខ្ញុំព្រះករុណាខ្ញុំសូមសំដែងការអបអរសាទរជាមួយបងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ ក្មួយៗសិស្សានុសិស្សទាំងអស់ គ្រប់ភូមិសិក្សា ទាំងសិស្សថ្មី ទាំងសិស្សចាស់ដែលបាននិងកំពុងរៀបចំខ្លួនប្រារព្ធពិធីអបអរសាទរទិវានេះនៅទូទាំងព្រះរាជាណាចក្រកម្ពុជាយើង ។

**ថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១៧** គឺជាថ្ងៃបើកទំព័រឆ្នាំសិក្សាថ្មី ដែលផ្តល់ឱកាសសម្រាប់សិស្ស- និស្សិតដែលជាកុលបុត្រ កុលធីតាជាទីស្រឡាញ់របស់យើងគ្រប់ៗគ្នាបានបន្តការសិក្សារៀនសូត្រទៅថ្នាក់ខ្ពស់បន្តទៀត និងជាថ្ងៃផ្តើមជីវិតសិក្សាដំបូងរបស់កុមារដែលទើបនឹងដល់អាយុត្រូវចូលសាលារៀន ។

ក្នុងទិវាដ៏មហោឡារិកនេះ ខ្ញុំព្រះករុណាខ្ញុំសូមសំដែងនូវមនោសញ្ចេតនារីករាយថ្លែងសារលិខិតជូនបងប្អូនជនរួមជាតិជាទីស្នេហា ដោយបង្ហាញនូវឆន្ទៈមោះមុត និងបុព្វហេតុយកចិត្តទុកដាក់លើកកម្ពស់វិស័យអប់រំ ពិសេសការជំរុញការកសាងធនធានមនុស្សឱ្យប្រកបដោយគុណភាព ។ យើងទាំងអស់គ្នាដឹងហើយថា

ការអប់រំល្អនឹងផ្តល់អត្ថប្រយោជន៍យ៉ាងធំធេងដល់បុគ្គល គ្រួសារ និងសង្គមជាតិទាំងមូល ព្រមទាំងទាក់ទាញការវិនិយោគ ធុរកិច្ចបន្ថែមទៀត ពោលការអប់រំល្អនឹងនាំដល់ការផ្គត់ផ្គង់ធនធានមនុស្ស កម្លាំងពលកម្មដែលមានចំណេះដឹង ជំនាញវិជ្ជាជីវៈឆ្លើយតបកាន់តែមានប្រសិទ្ធភាពទៅនឹងទីផ្សារការងារ និងតម្រូវការអភិវឌ្ឍ-សង្គមជាតិ ។ ជារួម ការព្រារព្ធទិវានេះនឹងដាស់ស្មារតីសិស្សានុសិស្សឱ្យយកចិត្តទុកដាក់ខ្ពស់លើការសិក្សារបស់ខ្លួនគ្រប់ពេល ខណៈការសិក្សារៀនសូត្រមិនត្រឹមតែអនុវត្តនៅក្នុងវ័យសិក្សាប៉ុណ្ណោះទេ ប៉ុន្តែគឺជាការងារមួយតម្រូវឱ្យមានការបន្តលើកកម្ពស់ និងការអភិវឌ្ឍន៍គ្មានទីបញ្ចប់ ដើម្បីធានានូវការផលិតធនធានមនុស្សប្រកបដោយគុណភាព មានសក្តានុពលសម្រាប់ការអភិវឌ្ឍសង្គម- សេដ្ឋកិច្ចជាតិ នាំឱ្យមានការរីកចម្រើនភាពសុខដុមរមនា និងការអភិវឌ្ឍប្រកបដោយចិរភាព ។

បច្ចុប្បន្នយើងដឹងថា ការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងបច្ចេកវិទ្យាព័តិមានបាននាំឱ្យសង្គមនីមួយៗទទួលនូវឧត្តមភាព និងនាំឱ្យមានការវិវឌ្ឍយ៉ាងខ្លាំងក្លាដល់វិស័យអប់រំផងដែរ ។ ប៉ុន្តែទោះបីជាបច្ចេកវិទ្យាមានការវិវឌ្ឍខ្លាំងយ៉ាងណាក៏ដោយ ក៏មិនអាចទៅជំនួសឱ្យធនធានមនុស្សបានទាំងស្រុងឡើយ ។ សង្គមជាតិមួយអាចរីកចម្រើន អាស្រ័យដោយសង្គមជាតិនោះសម្បូណ៌ដោយធនធានមនុស្សប្រកបដោយសក្តានុពល សមត្ថភាពដែលអាចប្រែក្លាយសង្គមជាតិនោះឱ្យមានការអភិវឌ្ឍន៍ឿនលឿនបានយ៉ាងឆាប់រហ័ស និងមានភាពកាន់តែរឹងមាំ ។ ក្នុងន័យនេះ ពិតណាស់ថា ធនធានមនុស្សនៅតែមានសារៈសំខាន់ ទោះក្នុងកាលៈទេសៈបែបណាក៏ដោយ ។

ក្នុងស្មារតីនេះ ខ្ញុំនៅតែយល់ថា ***«ការអប់រំល្អ គឺជាកូនសោសម្រាប់ដោះស្រាយរាល់បញ្ហាសង្គម និងសេដ្ឋកិច្ចជាតិ»*** ។ ជាក់ស្តែង ក្នុងយុគសម័យ ***សេដ្ឋកិច្ចពុទ្ធិ*** និង ***បច្ចេកវិទ្យាព័តិមាន*** នេះ ឧត្តមភាពប្រកួត-ប្រជែងកាន់តែមានសារៈសំខាន់នៅលើកត្តាធនធានមនុស្សដែលមានចំណេះដឹង ចំណេះធ្វើទូលំទូលាយ មានភាពច្នៃប្រឌិតខ្ពស់ និងមានជំនាញច្បាស់លាស់ ។ ប្រការនេះតម្រូវឱ្យរាជរដ្ឋាភិបាលត្រូវបន្តផ្តោតការយកចិត្តទុកដាក់កាន់តែខ្លាំងឡើងៗ ទៅលើការអភិវឌ្ឍ ***«មូលធនមនុស្ស»*** នេះ ដើម្បីធ្វើឱ្យមុតស្រួចក្នុងការទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ចកម្ពុជាឆាប់រហ័ស ទាំងក្នុងពេលបច្ចុប្បន្ន និងទៅអនាគត ។ កម្ពុជាក៏មានចក្ខុវិស័យច្បាស់លាស់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ក្នុងគោលដៅឆ្ពោះទៅកាន់**សង្គមពុទ្ធិ និងវិបុលភាព** ប្រជាជនមានចំណេះដឹង មានវប្បធម៌ជ្រៅជ្រះ មានផលិតភាព និងភាពប្រកួតប្រជែងខ្ពស់នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសកលភា-វូបនីយកម្ម ដោយឆ្លើយតបយ៉ាងសមស្រប និងទាន់ពេលវេលាទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល និងសេចក្តីត្រូវការរបស់ប្រទេសជាតិ ជាពិសេសក្នុងពេលដែលកម្ពុជាមាន ចក្ខុវិស័យប្រែក្លាយពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនាពេលបច្ចុប្បន្នទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ ២០៣០ និងក្លាយទៅជាប្រទេសមានចំណូលខ្ពស់នាឆ្នាំ ២០៥០ ខាងមុខ ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំសូមសំដែងនូវការកោតសរសើរចំពោះលោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ បុគ្គលិកអប់រំគ្រប់លំដាប់ថ្នាក់ មាតាបិតាអាណាព្យាបាលសិស្ស អាជ្ញាធរដែនដី និងដៃគូអភិវឌ្ឍទាំងអស់ដែលបានខិតខំប្រឹងប្រែងចំណាយទាំងកម្លាំងកាយ កម្លាំងចិត្ត ទាំងធនធានសម្រាប់ជួយជ្រោមជ្រែងគ្រប់សកម្មភាពក្នុងបុព្វហេតុរួមចំណែកកសាង និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យមានដំណើរការយ៉ាងរលូនទទួលបានជោគជ័យគួរជាទីមោទនៈក្នុងរយៈពេលកន្លងមកនេះ ។ ក្នុងនោះ ក្រសួងអប់រំយុវជន និងកីឡាបាននិងកំពុងអនុវត្តកម្មវិធីកែទម្រង់ស៊ីជម្រៅលើការងារអប់រំ ។ កិច្ចការនេះកាន់តែមានភាពម៉ត់ចត់ កាន់តែស៊ីចង្វាក់គ្នា ហើយផលទទួលមកវិញកាន់តែច្បាស់ ។ ជាក់ស្ដែងលទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំនេះ ដែលមានសិស្សជាប់និទ្ទេស A រហូតដល់ ៤២៤ នាក់ ។ នេះគឺជាសារឆ្លើយតប និងបង្ហាញអំពីការចូលរួមជ្រោមជ្រែង ជំរុញឱ្យគុណភាពអប់រំមានភាពល្អប្រសើរនាពេលកន្លងមកនិងពេលអនាគត ។

ទន្ទឹមនេះ ខ្ញុំព្រះករុណាខ្ញុំក៏សូមសំដែងនូវការអបអរសាទរ និងលើកទឹកចិត្តខ្ពស់ចំពោះក្មួយៗសិស្សានុសិស្សទាំងអស់ក្នុងការងាររៀនសូត្រ ទាំងចំពោះសិស្សទើបនឹងចូលរៀនថ្មី ទាំងសិស្សចាស់នៅគ្រប់ភូមិសិក្សា ហើយខ្ញុំព្រះករុណាខ្ញុំ សូមគាំទ្រជានិច្ចរិកចំពោះ **ថ្ងៃបើកបវេសនកាលឆ្នាំសិក្សាថ្មី ២០១៧-២០១៨** ដែលប្រារព្ធឡើងនៅទូទាំងប្រទេស ស្របគ្នានឹងពេលដែលប្រទេសជាតិស្ថិតក្នុងសុខសន្តិភាព វឌ្ឍនភាពនិងភាពសុខដុមរមនា ។

- *ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ*
- *បងប្អូនជនរួមជាតិជាទីស្នេហា !*

រាជរដ្ឋាភិបាលបានប្ដេជ្ញាហើយថា នឹងបន្តលើកកម្ពស់គោលការណ៍ «**ការអប់រំប្រកបដោយចីរភាព**» តាមរយៈការធានាឱ្យបាននូវលទ្ធភាពទទួលបានសេវាអប់រំប្រកបដោយសមធម៌ ដែលផ្ដល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនកម្ពុជាទាំងអស់ ជាពិសេសនៅតាមតំបន់ជនបទដាច់ស្រយាល និងនៅតាមតំបន់ព្រំដែនឱ្យទទួលការអប់រំជាមូលដ្ឋាន ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ។ កិច្ចការនេះនឹងត្រូវពង្រឹងនិងពង្រីកជាបន្តបន្ទាប់ ពីព្រោះការសិក្សារៀនសូត្រ គឺជារឿងដែលត្រូវធ្វើគ្មានទីបញ្ចប់ ។ ដូច្នេះ យើងទាំងអស់គ្នាត្រូវចូលរួមជំរុញឱ្យមានការអប់រំ បណ្ដុះបណ្ដាលឱ្យកាន់តែខ្ពស់ ដោយមិនត្រូវអនុញ្ញាតឱ្យកូនចៅណាម្នាក់ស្ថិតនៅក្រៅសេវាអប់រំនោះឡើយ ។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលមានការប្ដេជ្ញាចិត្តខ្ពស់ ក្នុងការខិតខំពុះពារបន្តដោះស្រាយរាល់ចំណុចសេសសល់ និងសំណូមពរនានា ក្នុងបុព្វហេតុលើកកម្ពស់វិស័យអប់រំ ទាំងអ្នកសិក្សានិងគ្រូបង្រៀនប្រកបដោយគុណភាព និងប្រសិទ្ធភាព ស្របតាមនិន្នាការរីកចម្រើន និងបទដ្ឋានអប់រំ ទាំងក្នុងតំបន់ និងពិភពលោក ។ ក្នុងន័យនេះ ក៏ទាមទារឱ្យយើងត្រូវប្រមូលកម្លាំង និងធនធានសរុបពីគ្រប់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីរួមគ្នាគាំទ្រលើកកម្ពស់វិស័យអប់រំជាតិ ដោយមិនឱ្យនរណាម្នាក់នៅក្រៅសេវាអប់រំ និងត្រូវបណ្ដុះបណ្ដាលកូនចៅជាយុវជន

ជំនាន់ក្រោយឱ្យក្លាយជា**មូលធនមនុស្ស** ដែលពោរពេញដោយសមត្ថភាពពេញលេញ ជំនាញខ្ពស់គ្រប់ៗគ្នា និងប្រកបដោយសក្ដានុពល ។

ជាមួយនេះ ខ្ញុំព្រះករុណាខ្ញុំក៏សូមអំពាវនាវឱ្យជនរួមជាតិយើងទាំងអស់ សូមនាំគ្នាយកកូនចៅទៅចុះឈ្មោះចូលរៀននៅដើមបវេសនកាលឆ្នាំសិក្សាថ្មីនេះឱ្យបានគ្រប់ៗគ្នា និងចូលរួមតាមដានការសិក្សារបស់កូនចៅយើងបន្ថែមទៀត ឱ្យបានតព់មត់ ។ ក្នុងនោះដែរ អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវជួយសម្របសម្រួល និងផ្តល់លទ្ធភាពជូនដល់ពួកគេបានចូលរៀន និងរៀនបានចប់តាមកម្រិតថ្នាក់យ៉ាងតិច ៩ ឆ្នាំ និងជំរុញគាំទ្រឱ្យពួកគេបានសិក្សារៀនសូត្រចប់ភូមិសិក្សារហូតដល់ឧត្តមសិក្សា ឱ្យប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ ។

ដោយឡែក ក្នុងឱកាសបើកបវេសនកាលឆ្នាំសិក្សាថ្មីនេះ ខ្ញុំព្រះករុណាខ្ញុំសូមផ្ដាំទៅក្មួយៗសិស្សានុសិស្ស និងយុវជន យុវនារីទាំងអស់ឱ្យខិតខំរៀនសូត្រឱ្យខាប់ខួន ព្រមទាំងចូលរួមក្នុងសកម្មភាពនានា ដើម្បីគាំទ្រដំណើរការអភិវឌ្ឍសាលារៀន និងសង្គមជាតិរបស់យើង ។ ដោយឡែក ក្មួយៗសិស្សានុសិស្សទាំងអស់ត្រូវចាំថា បើយើងស្រឡាញ់ខ្លួន ស្រឡាញ់ឪពុកម្ដាយ និងស្រឡាញ់អនាគតរុងរឿង គឺត្រូវនៅឱ្យឆ្ងាយពីគ្រឿងញៀន និងត្រូវចេះណែនាំចំពោះមិត្តភក្ដិអំពីគ្រោះថ្នាក់ នៃការប្រើប្រាស់គ្រឿងញៀន និងត្រូវជៀសវាងការសេពគប់មិត្តដែលប្រព្រឹត្តរឿងអបាយមុខ ។ ទន្ទឹមនោះ ចូរក្មួយៗប្រតិបត្តិ ច្បាប់ចរាចរណ៍ឱ្យបានខាប់ខួន ដោយត្រូវចេះយោគយល់ និងមានអធ្យាស្រ័យគ្នា ក្នុងពេលបើកបរ ដើម្បីធានាបាននូវសុវត្ថិភាពផ្ទាល់ខ្លួនផង និងអ្នកដទៃផង ក៏ដូចជារក្សាបាននូវសេចក្ដីថ្លៃថ្នូរដល់សង្គមជាតិយើងផង ។

ចំពោះមុខនេះ ខ្ញុំព្រះករុណាខ្ញុំស្នើសុំឱ្យមាតាបិតា ឬ អ្នកអាណាព្យាបាលសិស្ស សហគមន៍ និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវរួមចំណែកឱ្យបានខ្លាំងក្លា ដើម្បីពង្រឹងខឿនសន្តិសុខជាតិឱ្យកាន់តែរឹងមាំតាមរយៈការបន្តជំរុញចលនាអនុវត្តគោលនយោបាយ **«ភូមិ- ឃុំមានសុវត្ថិភាព»** ឱ្យមាននិរន្តភាព និងផុលផុស ហើយចូលរួមយ៉ាងសកម្មក្នុងការជួយអប់រំកូនចៅទាំងផ្នែកសុខភាព ចំណេះដឹង និងសីលធម៌ ដើម្បីឱ្យពួកគេក្លាយជាធនធានមនុស្សពោរពេញដោយសមត្ថភាព ទេពកោសល្យ និងសក្ដានុពល ព្រមទាំងទទួលបានសម្បទាសម្រាប់ការចាប់យកវិជ្ជា បំណិន និងចរិយាធម៌ ឈានទៅកសាងអនាគតមួយដ៏រុងរឿង ព្រមទាំងបន្តលើកកម្ពស់កិត្តិយសសង្គមជាតិឱ្យស័ក្តិសមជាប្រជាជន ដែលមានឈាមជ័រតភ្ជាប់គ្នាពីសម័យមហានគរដ៏រុងរឿងនៃយើង ។

ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំសូមថ្លែងអំណរព្រះគុណចំពោះព្រះតេជគុណព្រះសង្ឃគ្រប់ព្រះអង្គ សូមអរគុណចំពោះបងប្អូនជនរួមជាតិ លោកគ្រូ អ្នកគ្រូ បុគ្គលិកអប់រំ សាស្ត្រាចារ្យទាំងអស់ ព្រមទាំងដៃគូអភិវឌ្ឍវិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល និងសប្បុរសជននានា ដែលតែងតែបានរួមចំណែកកសាង និងអភិវឌ្ឍវិស័យអប់រំនៅកម្ពុជាឱ្យមានដំណើរការរីកចម្រើនគួរជាទីមោទនៈក្នុងរយៈកាលកន្លងមកនេះ និងសូមបន្ត

ជួយឧបត្ថម្ភគាំទ្រ និងផ្តល់នូវកិច្ចសហការដ៏ល្អបែបនេះតទៅមុខទៀត ដើម្បីបុព្វហេតុនៃការអភិវឌ្ឍវិស័យអប់រំ បណ្តុះបណ្តាលធនធានមនុស្សកម្ពុជា ។

ជាទីបញ្ចប់ ក្នុងនិកាល**ប្រកាសបើកបវេសនកាលឆ្នាំសិក្សា ២០១៧-២០១៨** នេះ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរព្រះតេជគុណ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងសូមជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ក្មួយៗសិស្សានុសិស្ស និស្សិត និងបងប្អូនជនរួមជាតិទាំងអស់នៅទូទាំងប្រទេស សូមប្រកបដោយពុទ្ធពរទាំងបួនប្រការ ***អាយុ វណ្ណៈ សុខៈ ពលៈ*** កុំបីឃ្លៀងឃ្លាតឡើយ ៕

***សូមអរព្រះគុណ និងសូមអរគុណ !***

*រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**